ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សាលក្រមព្រហ្មទណ្ឌលេខ: ០១ "ខ"

ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨៦

ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្ត កំពង់ឆ្នាំង

បើកសវនាការជាសាធារណៈនៅសាលសវនាការនាសាលាដំបូងខេត្ត កំពង់ឆ្នាំង។

- កាលបរិច្ឆេទបើកសវនាការ: នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៨ ព្រឹក។
- កាលបរិច្ឆេទប្រកាសសាលក្រម: នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៨ រសៀល។

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងអយ្យការ</u>**

លោកស្រី [redacted] ព្រះរាជអាជ្ញារង

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ៨៦ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ដែលមានជនជាប់ចោទ:

១.ឈ្មោះ [redacted] **យ៉ាំងងា** ភេទប្រុស អាយុ៤០ឆ្នាំ ជាតិវៀតណាម មុខរបរនេសាទ ទីកន្លែងកំណើត និងទីលំនៅនៅ[redacted]ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូនចំនួន ០៣នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

២.ឈ្មោះ [redacted] **យ៉ាំងស៊ីវ** ភេទប្រុស អាយុ៥០ឆ្នាំ ជាតិវៀតណាម មុខរបរនេសាទ កើតនៅភូមិអន្លង់ស្នោ ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ទីលំនៅនៅ[redacted] ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។ ឪពុកឈ្មោះ [redacted]ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted]"រ" មានកូនចំនួន ០៤នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ដោយមានលោក [redacted] **ឡាយ** និងលោក[redacted]**អុល** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរខាងលើ។ ៚

ត្រូវបានជាប់ចោទពីបទ: **នេសាទដោយប្រើឧបករណ៍ទំនើប** ប្រព្រឹត្តនៅភូមិប្រម៉ាល់ ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ០៨.០២.២០១៥។ បទល្មើសព្រហ្មទណ្ឌ និងទោស ដែលមានចែងក្នុងមាត្រា ៩៨ ចំណុច៦ កថាខណ្ឌ២ នៃច្បាប់ស្តីពីជលផល។

តាមដីកាដំណោះស្រាយលេខ: ៣៤៧ ចុះថ្ងៃទី ១៣.១០.២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

## ឯអង្គហេតុនៃរឿងមានដូចតទៅ:

កាលពីថ្ងៃទី ០៨.០២.២០១៥ វេលាម៉ោង ២០ និង៣០នាទីយប់ នៅចំណុចក្បាលកោះចោរ ភូមិប្រម៉ាល់ ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កើតមានករណី នេសាទដោយខុសច្បាប់ ដែលបង្កឡើងដោយឈ្មោះ [redacted] យ៉ាំងងា និង [redacted] យ៉ាំងស៊ីវ បានប្រើឧបករណ៍នេសាទខុសច្បាប់ ដើម្បីនេសាទត្រីដោយគ្មានច្បាប់អនុញ្ញាត។

## នាពេលសវនាការ

**ក្រោយពីបាន:**

- ស្តាប់ចម្លើយជនជាប់ឈ្មោះ [redacted] យ៉ាំងស៊ីវ និង [redacted] យ៉ាំងងា
- ស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] គឹមអឿន និង [redacted] សារឿន
- ស្តាប់ចម្លើយសាក្សីជាសមត្ថកិច្ចឈ្មោះ [redacted] សុង
- ស្តាប់អំណានចម្លើយសមត្ថកិច្ចឈ្មោះ [redacted] ស៊ីហាក់
- ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ស្តាប់ការកត់សម្គាល់ខ្លីៗ និងជាធ្វើសំណូមពររបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

-ឃើញថានៅក្នុងសំណុំរឿងនេះ ការកសាងសំណុំរឿងមក អយ្យការបានធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងមកស៊ើបសួរ លេខ ៣៧១ ចុះថ្ងៃទី ០១.០២.២០១៥ ទាក់ទងទៅនឹងបទល្មើស មនុស្សឃាតដោយចេតនាដោយអចេតនា និងនេសាទដោយខុសច្បាប់ តាមមាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៨ ចំណុច៦ នៃច្បាប់ភូមិបាល។ ហើយនៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ១៤៨២ ចុះថ្ងៃទី ២៥.០៦.២០១៥ និង ដីកាដំណោះស្រាយ លេខ ២២២ ចុះថ្ងៃទី ៣០.០៦.២០១៥ នៅតែរក្សាការចោទប្រកាន់នោះដដែលដោយពុំមានការកែប្រែអ្វីឡើយ។

-ឃើញថានៅក្នុងសាលក្រមរបៀបលេខ ០១(ជ) ចុះថ្ងៃទី ២៥.០៥.២០១៦ បានសម្រេចចាត់របៀបសំណុំរឿងនេះទៅតំណាងអយ្យការដើម្បីបើកការស៊ើបសួរ លើជនជាប់ចោទទាំងពីរនាក់ ពីបទ នេសាទដោយខុសច្បាប់ តាមមាត្រា ៩៨ ចំណុច៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។ ដោយសាលក្រមរបៀបមិនមានបានសម្រេចពីបទ មនុស្សឃាតដោយអចេតនា ថាត្រូវធ្វើយ៉ាងណានៅឡើងទេ ពោលគឺទាក់ទងទៅនឹងបទល្មើសមនុស្សឃាតដោយអចេតនាមិនទាន់ត្រូវបានសម្រេចបញ្ចប់ឡើយ។ ៗ

Scanned by CamScanner

-ឃើញថា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៣៥៣ ចុះថ្ងៃទី ១២.០៧.២០១៦, ដីកាសន្និដ្ឋានស្ថាពរលេខ ២០០០ ចុះថ្ងៃទី ១០.១០.២០១៦ និង ដីកាដំណោះស្រាយលេខ ៣៤៧ ចុះថ្ងៃទី ១៣.១០.២០១៦ ចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីរនាក់នៅក្នុងសំណុំរឿងដដែលនេះ តែបទល្មើសមួយគឺ ធ្វើនេសាទដោយឧបករណ៍ទំនើប តាមមាត្រា ៩៨ ចំណុច៦ កថាខណ្ឌ២ នៃច្បាប់ស្តីពីជលផល ដោយបាត់នូវបទល្មើសមួយគឺ បទមនុស្សឃាតដោយអចេតនា ដែលមិនទាន់បានសម្រេចសេចក្តីនៅឡើយ។

-ឃើញថាក្នុងសំណុំរឿងនេះផងដែរ ទាក់ទងទៅនឹងវត្ថុតាងនៃបទល្មើស ពុំមានបញ្ជូនមកតុលាការ ដើម្បីឱ្យតុលាការបង្គាប់ឱ្យធ្វើការថែរក្សានោះទេ។ ហើយផលដែលកើតចេញមកពីអំពើល្មើសក៏ពុំមានដែរ

*ដើម្បីឱ្យការសម្រេចសេចក្តីប្រកបទៅដោយយុត្តិធម៌ដល់ភាគីទាំងអស់នៅក្នុងសំណុំរឿងនេះ គប្បីតុលាការធ្វើការចាត់របៀប ដើម្បីឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ជាថ្មីម្តងទៀតទាំងពីរបទល្មើស ហើយនឹងបង្គាប់ឱ្យខាងជំនាញដែលបានរក្សាទុកវត្ថុតាងនេះ ប្រគល់វត្ថុតាងមកតុលាការដើម្បីធ្វើការបង្គាប់ឱ្យអ្នកជំនាញថែរក្សាវត្ថុតាងទៅតាមផ្លូវច្បាប់។*

*យោងតាមកំណត់ហេតុបំភ្លឺរបស់សាក្សីជាសមត្ថកិច្ចជំនាញឈ្មោះ [redacted] សីហាក់ បានបញ្ជាក់ថា ទាក់ទងទៅនឹងការនេសាទរបស់ជនជាប់ចោទទាំងពីរវាល្មើសទៅនឹងមាត្រា ៩៤ ចំណុច២ កថាខណ្ឌ២ នៃច្បាប់ស្តីពីជលផល ដែលវាខុសគ្នាទៅនឹងការបញ្ជូនមកជំនុំជម្រះ ពីបទ នេសាទដោយប្រើឧបករណ៍ទំនើប តាមមាត្រា ៩៨ ចំណុច៦ កថាខណ្ឌ២ នៃច្បាប់ស្តីពីជលផល ដែលគប្បីឱ្យមានការអញ្ជើញអ្នកជំនាញមកបំភ្លឺឱ្យបានច្បាស់ដើម្បីផ្តល់យុត្តិធម៌ដល់ជនជាប់ចោទផងដែរ។*

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១-***ចាត់របៀប***លើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៦ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទៅតំណាងអយ្យការដើម្បីបើកការស៊ើបសួរជាថ្មី លើជនជាប់ចោទទាំងពីរដូចមានរាយនាមក្នុងសំណុំរឿង ពីបទ **មនុស្សឃាតដោយអចេតនា និងនេសាទដោយខុសច្បាប់។**

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
កំពង់ឆ្នាំង ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨
**ក្រឡាបញ្ជី**
[redacted]

បានឃើញ និងឯកភាព
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]

Scanned by CamScanner